ABA BANK

NATIONAL BANK OF CANADA GROUP

# សង្ខេបអំពីសកម្មភាព ទំនួលខុសត្រូវសង្គម និងសុខុមាលភាពសហគមន៍របស់ធនាគារ ABA អំឡុងឆ្នាំ 2021 - 2023

ក្នុងនាមជាសាជីវកម្មដ៏សកម្មនៅកម្ពុជា ធនាគារ ABA
បន្តចូលរួមក្នុងគំនិតផ្តួចផ្តើមដើម្បីជួយសហគមន៍មូលដ្ឋាន
និងរួមចំណែកដល់សុខុមាលភាពសហគមន៍ទាំងនោះ។
ខាងក្រោមនេះជាសេចក្តីសង្ខេបខ្លីៗនៃគម្រោងសំខាន់ៗ
ដែលធនាគារបានធ្វើនាពេលថ្មីៗនេះ។

# ការលើកស្ទួយសហគមន៍ / កីឡាជាតិ




## ព្រឹត្តិការណ៍កីឡាស៊ីហ្គេម 2023

ធនាគារ ABA ជាអ្នកឧបត្ថម្ភផ្តាច់មុខលើវិស័យធនាគារ និងលើសេវាទូទាត់ឌីជីថល សម្រាប់ព្រឹត្តិការណ៍ស៊ីហ្គេម 2023 ដោយបានឧបត្ថម្ភជាទឹកប្រាក់សរុប 1,650,000 ដុល្លារអាមេរិក។ ការឧបត្ថម្ភនេះ រួមបញ្ចូលទាំងការគាំទ្រជាថវិកា និងការគាំទ្រផ្សេងៗមិនមែនថវិកា ដោយធនាគារបានចូលរួមផ្សព្វផ្សាយអំពីព្រឹត្តិការណ៍នេះ និងលើកកម្ពស់ស្មារតីកីឡានៅក្នុងប្រទេស។ ក្រៅពីនេះ សេវាកម្មនានារបស់ធនាគារ ក៏ត្រូវបានជ្រើសរើសសម្រាប់ការទូទាត់ ដែលពាក់ព័ន្ធនឹងព្រឹត្តិការណ៍នេះផងដែរ។

ការឧបត្ថម្ភព្រឹត្តិការណ៍ស៊ីហ្គេម ដែលរៀបចំឡើងជាលើកដំបូងនៅក្នុងប្រទេសកម្ពុជា ឆ្លុះបញ្ចាំងអំពីការប្តេជ្ញាចិត្តរបស់ធនាគារ ABA ក្នុងការគាំទ្រវិស័យកីឡា និងទេសចរណ៍របស់កម្ពុជា។

# ការថែទាំសុខភាព / សុខុមាលភាពសហគមន៍



## មូលនិធិ Covid-19 របស់រាជរដ្ឋាភិបាល

ធនាគារ ABA បរិច្ចាគទឹកប្រាក់ចំនួន **មួយលានដុល្លារអាមេរិក ($1,000,000)** ដើម្បីគាំទ្រកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការទប់ស្កាត់ជំងឺរីករាលដាល។ ដោយអនុវត្តតាមបេសកកម្ម និងគុណតម្លៃសាជីវកម្មរបស់ខ្លួន ធនាគារ ABA ប្តេជ្ញាចិត្តគាំទ្រនូវគំនិតផ្តួចផ្តើមក្នុងគោលបំណងប្រយុទ្ធប្រឆាំងនឹងវីរុសកូវីដ-19។ ចាប់តាំងពីពេលចាប់ផ្តើមនៃការរីករាលដាលវីរុសនៅក្នុងប្រទេសកម្ពុជា ធនាគារ ABA បានរៀបចំយុទ្ធនាការរៃអង្គាសប្រាក់ និងបរិច្ចាគថវិកាតាមរយៈគំនិតផ្តួចផ្តើមរបស់ធនាគារជាតិនៃកម្ពុជា និងសមាគមធនាគារនៅកម្ពុជា។

បន្ថែមលើការគាំទ្រផ្នែកថវិកា កម្មវិធី ABA Mobile ដ៏ទំនើបរបស់ធនាគារ ត្រូវបានប្រើប្រាស់ជាឧបករណ៍សម្រាប់រៃអង្គាសប្រាក់នៅក្នុងគំនិតផ្តួចផ្តើមរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីទិញវ៉ាក់សាំងការពារវីរុសកូវីដ-19 ផងដែរ។




## សមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ

ធនាគារ ABA បានចុះអនុស្សរណៈយោគយល់គ្នា ជាមួយសមាគមគ្រូពេទ្យស្ម័គ្រចិត្តយុវជនសម្តេចតេជោ (TYDA) ដើម្បីផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់សមាគម។ ថវិកាសប្បុរសធម៌ចំនួន **មួយសែនដុល្លារអាមេរិក ($ 100,000)** របស់ ABA ជូនដល់ TYDA សម្រាប់ការងារសំខាន់ៗក្នុងការផ្តល់សេវាព្យាបាល និងថែទាំសុខភាពដោយឥតគិតថ្លៃដល់សហគមន៍ជនបទទូទាំងប្រទេស។

TYDA ជាអង្គការសប្បុរសធម៌មិនរកប្រាក់កម្រៃត្រូវបានបង្កើតឡើង ដើម្បីយកចិត្តទុកដាក់តាមដានតម្រូវការផ្នែកវេជ្ជសាស្ត្រនៅក្នុងសហគមន៍ក្រីក្រក្នុងប្រទេសកម្ពុជា និងសម្រាលបន្ទុកផ្នែកវេជ្ជសាស្ត្ររបស់ប្រជាជន។




## មន្ទីរពេទ្យបង្អែកស្រុកក្រូចឆ្មារថ្មី

ធនាគារ ABA បានបរិច្ចាគទឹកប្រាក់ចំនួន **បីម៉ឺនប្រាំពាន់ដុល្លារអាមេរិក ($35,000)** ដល់មន្ទីរពេទ្យបង្អែកស្រុកក្រូចឆ្មារ ក្នុងខេត្តត្បូងឃ្មុំ។ ទឹកប្រាក់នេះ ត្រូវបានបរិច្ចាគជូនមន្ទីរពេទ្យសម្រាប់ការសាងសង់អគារទី 2 ដើម្បីផ្តល់ការព្យាបាលដល់ ប្រជាជនប្រមាណ 469,000 នាក់ (ក្នុងនោះ 239,000 នាក់ជាស្រ្តី) ដែលរស់នៅក្នុងស្រុកចំនួនបួនក្បែរនោះ និងលើកកម្ពស់គុណភាពនៃការធ្វើរោគវិនិច្ឆ័យ។

មន្ទីរពេទ្យបង្អែកស្រុកក្រូចឆ្មារ ត្រូវបានបង្កើតឡើងក្នុងឆ្នាំ 1966 ជាមួយនឹងចក្ខុវិស័យរបស់ខ្លួន ក្នុងការអនុវត្តគោលនយោបាយ និងយុទ្ធសាស្រ្តសុខាភិបាលរបស់រាជរដ្ឋាភិបាលក្នុងខេត្តត្បូងឃ្មុំ។




## គម្រោងសម្តេចតេជោសម្រាប់ គោលដៅកម្ពុជាគ្មានមីន

ធនាគារ ABA បានបរិច្ចាគទឹកប្រាក់ចំនួន **ពីរសែនដុល្លារអាមេរិក ($200,000)** ជូនអាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (CMAA) សម្រាប់គម្រោង សម្តេចតេជោ សម្រាប់សកម្មភាពមីន ក្រោមគំនិតផ្តួចផ្តើមរបស់សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន។ ថវិកាសប្បុរសធម៌នេះ នឹងត្រូវបានយកទៅប្រើប្រាស់ ដើម្បីជំរុញការងារបោសសម្អាតមីនឆ្ពោះទៅកាន់គោលដៅ កម្ពុជាគ្មានមីនឆ្នាំ 2025។

CMAA ត្រូវបានបង្កើតឡើងក្នុងឆ្នាំ 2000 ក្រោមការដឹកនាំផ្ទាល់របស់នាយករដ្ឋមន្ត្រី សម្រាប់ការគ្រប់គ្រងត្រួតពិនិត្យ និងសម្របសម្រួលរាល់សកម្មភាពដោះមីន។




## កាកបាទក្រហមកម្ពុជា

ធនាគារ ABA ចូលរួម វិភាគទានសប្បុរសធម៌ចំនួន **ពីរសែនដុល្លារអាមេរិក** ($200,000) ជូនកាកបាទក្រហមកម្ពុជា។ ថវិកាសប្បុរសធម៌ពី ABA នឹងយកទៅប្រើប្រាស់ ដើម្បីបម្រើសកម្មភាពមនុស្សធម៌របស់កាកបាទក្រហមកម្ពុជាទូទាំងប្រទេស។ កាកបាទក្រហមកម្ពុជា បានកំពុងដំណើរការបេសកកម្មរបស់ខ្លួននៅក្នុងប្រទេសកម្ពុជាអស់ជាច្រើនទសវត្សមកហើយ ហើយបានដើរតួយ៉ាងសំខាន់អំឡុងពេលរីករាលដាលនៃជំងឺកូវីដ-19 និងយុទ្ធនាការចាក់វ៉ាក់សាំង ដែលរៀបចំដោយរាជរដ្ឋាភិបាលកម្ពុជា។

កាកបាទក្រហមកម្ពុជា ជាអង្គការសប្បុរសធម៌ឈានមុខគេនៅកម្ពុជា ដែលត្រូវបានបង្កើតឡើងនៅឆ្នាំ 1955។ អង្គការនេះ ត្រូវបានទទួលស្គាល់ជាផ្លូវការពីរាជរដ្ឋាភិបាលកម្ពុជាថា ជាជំនួយការឲ្យអាជ្ញាធរសាធារណៈ នៅក្នុងវិស័យមនុស្សធម៌ ដោយចូលរួមក្នុងសកម្មភាពជាច្រើនរួមមាន កម្មវិធីជំនួយសង្គ្រោះគ្រោះមហន្តរាយផ្សេងៗ កិច្ចខិតខំប្រឹងប្រែងផ្នែកមនុស្សធម៌ និងសកម្មភាពសុខុមាលភាពនានាក្នុងប្រទេសកម្ពុជា។




## អាកាសយានដ្ឋានអន្តរជាតិតេជោ

ធនាគារ ABA វិនិយោគនូវទឹកប្រាក់ចំនួន **សាមសិបលានដុល្លារអាមេរិក ($30,000,000)** លើសញ្ញាបណ្ណសាជីវកម្ម ដើម្បីចូលរួម ក្នុងការអភិវឌ្ឍអាកាសយានដ្ឋានអន្តរជាតិតេជោ។ ដោយមានការគាំទ្រដ៏ខ្ពង់ខ្ពស់ពីសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អាកាសយានដ្ឋាននេះ នឹងក្លាយជាមជ្ឈមណ្ឌលដឹកជញ្ជូនដ៏ធំ ដែលនឹងជួយបង្កើនការវិនិយោគរបស់ប្រទេស និងការទាក់ទាញផ្នែកទេសចរណ៍។

ការវិនិយោគនេះ ធ្វើឡើងស្របតាមបេសកកម្មរបស់ ABA ដែលប្រតិបត្តិការក្នុងនាមជាដៃគូជាមួយធុរកិច្ចកម្ពុជានិងប្រជាជនកម្ពុជា។




## កម្មវិធី តន្ត្រីដើម្បីកុមារ

ធនាគារ ABA បានចូលរួមឧបត្ថម្ភកម្មវិធី តន្ត្រីដើម្បីកុមារ ដើម្បីកៀរគរមូលនិធិ ជូនមន្ទីរពេទ្យកុមារអង្គរ។ ការប្រគុំតន្ត្រីនេះ មានការចូលរួមសំដែងដោយផ្ទាល់ ពីតារាចម្រៀងដ៏មានប្រជាប្រិយភាពគឺ លោក ម៉ម ពេជ្ជរិទ្ធ ដើម្បីរៃអង្គាសថវិកាជូនមន្ទីរពេទ្យ។

ការឧបត្ថម្ភរបស់ធនាគារ ABA បានបង្ហាញអំពីការប្តេជ្ញាចិត្តរបស់ខ្លួន ក្នុងការគាំទ្រវិស័យសុខាភិបាល និងគំនិតផ្តួចផ្តើមផ្នែកសុខាភិបាលនៅក្នុងប្រទេស។

# ការគាំទ្រដល់សហគ្រិនភាព




## ពិព័រណ៍ផលិតផលសហគ្រិនស្ត្រី 2023

ធនាគារ ABA បានចូលរួមជា Gold Sponsor នៃពិព័រណ៍ផលិតផលសហគ្រិនស្ត្រី 2023 (CWEA)។ ពិព័រណ៍នេះ បានប្រព្រឹត្តទៅពីថ្ងៃទី 29-31 ខែមីនា ឆ្នាំ 2023 នៅផ្សារទំនើបអូឡាំព្យា រាជធានីភ្នំពេញ។

ពិព័រណ៍ផលិតផលសហគ្រិនស្ត្រី ដែលមានរយៈពេល 3ថ្ងៃនេះ មានគោលបំណងគាំទ្រ និងបង្កើនភាពអង់អាច របស់សហគ្រិនស្ត្រី ដោយផ្តល់ទីតាំង (ស្តង់) មួយ ដើម្បីឲ្យពួកគាត់ដាក់បង្ហាញផលិតផល និងសេវាកម្មរបស់ខ្លួន, ផ្លាស់ប្តូរមតិយោបល់ និងកសាងបណ្តាញទំនាក់ទំនង ក្នុងចំណោមសហគ្រិនស្ត្រី។

ការចូលរួមរបស់ធនាគារ បានបង្ហាញនូវឆន្ទៈរបស់ខ្លួន ក្នុងការគាំទ្រសហគមន៍ និងសហគ្រិននៅក្នុងប្រទេសកម្ពុជា ក៏ដូចជាការប្តេជ្ញាចិត្តរបស់ធនាគារ ក្នុងការលើកកម្ពស់កំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងសមភាពយេនឌ័រ។



## កម្មវិធីពន្លឿនអាជីវកម្មថ្នាលឌីជីថល រដូវកាលទី 2

ធនាគារ ABA បានក្លាយជា Platinum Sponsor នៃកម្មវិធីពន្លឿនអាជីវកម្មថ្នាលឌីជីថលរដូវកាលទី 2 (DPA) ដើម្បីជំរុញសេដ្ឋកិច្ចឌីជីថលកម្ពុជា តាមរយៈការប្រឹក្សាយោបល់ជាមួយគ្រូតម្រង់ទិស និងឱកាសទទួលបានប្រាក់ឧបត្ថម្ភចំនួន **ប្រាំពាន់ដុល្លារអាមេរិក ($5,000)** សម្រាប់ធុរកិច្ចបង្កើតថ្មី។

កម្មវិធី DPA ត្រូវបានរៀបចំឡើងដោយមានរយៈពេល 16 សប្តាហ៍ ដើម្បីគាំទ្រធុរកិច្ចឌីជីថលថ្មីៗ ដែលអាចផ្តល់នូវថ្នាលឌីជីថល ប្រកបដោយនវានុវត្តន៍ (ការអនុវត្តបែបថ្មី) សម្រាប់សហគ្រាសធុនមីក្រូ តូច និងមធ្យម (MSMEs) ហើយចាប់ផ្តើមអនុវត្តធុរកិច្ចបែបឌីជីថល ទៅក្នុងប្រតិបត្តិការអាជីវកម្មរបស់ពួកគេ។

ភាពជាដៃគូរបស់ធនាគារ ABA ជាមួយកម្មវិធីនេះ ឆ្លុះបញ្ចាំងពីឆន្ទៈរបស់ខ្លួនក្នុងការគាំទ្រនវានុវត្តន៍ និងសហគ្រិនភាពនៅក្នុងប្រទេស។




## មហោស្រពសហគ្រិនវ័យក្មេងអាស៊ាន

ធនាគារ ABA បានគាំទ្រ មហោស្រពសហគ្រិនវ័យក្មេងអាស៊ាន (AYE) 2022 រៀបចំឡើងស្របគ្នានឹងឱកាសដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះសម្រាប់កិច្ចប្រជុំកំពូលអាស៊ាន 2022។ ទឹកប្រាក់ឧបត្ថម្ភស្មើនឹង **ដប់ពាន់ដុល្លារអាមេរិក** ($10,000)។

មហោស្រព AYE ប្រមូលផ្តុំដោយសហគ្រិនវ័យក្មេង ពីសមាជិកក្រុមប្រឹក្សាសហគ្រិនវ័យក្មេងអាស៊ាន(AYEC) និងដៃគូសន្ទនារបស់ខ្លួន។ មហាស្រពនេះ មានគោលបំណងជួយដល់ធុរកិច្ច និងសហគ្រិនវ័យក្មេង ក្នុងការជម្នះរាល់បញ្ហាបង្កដោយកូវីដ19 តាមរយៈឌីជីថលុបនីយកម្ម, ភាពជាអ្នកដឹកនាំ, កិច្ចសហការ, និងការចូលរួមពីស្ត្រី ក្នុងការដោះស្រាយបញ្ហាប្រឈមជាច្រើន។

តាមរយៈការឧបត្ថម្ភនេះ ABA បានរួមចំណែកដល់ការអភិវឌ្ឍសហគ្រាសមីក្រូ ធុនតូច និងមធ្យម (MSME) និងការកសាងអេកូស៊ីស្ទឹមសហគ្រិនភាពក្នុងប្រទេសកម្ពុជា ពិសេសក្នុងការគាំទ្រសហគ្រិនវ័យក្មេង និងធុរកិច្ចថ្មី (startups) ដែលត្រូវបានចាត់ទុកជាសសរស្តម្ភដ៏សំខាន់មួយក្នុងការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយស្ថិរភាព។

# ចំណេះដឹង និងបរិយាបន្នហិរញ្ញវត្ថុ



## ចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់កុមារ

ABA បានឧបត្ថម្ភថវិកាចំនួន **មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក ($15,000)** ដល់កម្មវិធី ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ដែលផ្តួចផ្តើមដោយធនាគារជាតិនៃកម្ពុជា។ ទឹកប្រាក់ឧបត្ថម្ភនេះ ត្រូវបានប្រើប្រាស់ដើម្បី បោះពុម្ពសៀវភៅកុមារ ក្រោមចំណងជើងថា “តោះ! និយាយពីលុយ” ចំនួន 5,000 ក្បាល ដែលត្រូវបានចែកជូនដល់សិស្សានុសិស្សនៅសាលាបឋមសិក្សាមុខនាគ ក្នុងខេត្តសៀមរាប។

កម្មវិធីនេះ មានគោលដៅ បញ្ជ្រាបខ្លឹមសារចំណេះដឹងផ្នែកហិរញ្ញវត្ថុទៅក្នុងវិស័យអប់រំ ដូចជា ផែនការរៀបចំកញ្ចប់ថវិកា និងវប្បធម៌នៃការសន្សំប្រាក់ ដែលជួយឲ្យសិស្សានុសិស្សចេះត្រិះរិះពិចារណាស៊ីជម្រៅ និងដឹងថាការទុកដាក់ប្រាក់នៅគ្រឹះស្ថានហិរញ្ញវត្ថុមានសុវត្ថិភាព និងប្រយោជន៍កម្រិតណា។




## កម្មវិធីចំណេះដឹងផ្នែកហិរញ្ញវត្ថុសម្រាប់ជនជាតិដើមភាគតិច

ការពង្រឹងសមត្ថភាពជនជាតិដើមភាគតិចតាមរយៈ ចំណេះដឹងផ្នែកហិរញ្ញវត្ថុ ជាកម្មវិធីចំណេះដឹងហិរញ្ញវត្ថុ ដែលរៀបចំឡើងដោយធនាគារ ABA និងក្រុមហ៊ុនកាណាដា Angkor Resources Corp. ដើម្បីអភិវឌ្ឍ ចំណេះដឹង និងជំនាញរបស់សហគមន៍ជនជាតិដើមភាគតិចក្នុងខេត្តរតនគិរី ឲ្យរីកចម្រើនទាំងផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់ពួកគេប្រកបដោយភាពឆ្លាតវៃ និងសុវត្ថិភាព។

កម្មវិធីនេះបានផ្លាស់ប្តូរជីវិតរស់នៅរបស់ជនជាតិដើមភាគតិច ជាមួយនឹងជំនាញហិរញ្ញវត្ថុសំខាន់ៗ ដូចជាការធ្វើផែនការរយៈពេលវែង ថវិកាក្នុងគ្រួសារ ការគ្រប់គ្រងបំណុល និងការទូទាត់សងបំណុល និង ការគ្រប់គ្រងថវិកា និងការវិនិយោគប្រចាំថ្ងៃ។




## គំនិតផ្តួចផ្តើមតាមតំបន់លើចំណេះដឹងហិរញ្ញវត្ថុ - ទិវាសន្សំអាស៊ាន 2022

ធនាគារ ABA បានក្លាយជា Diamond Sponsor ក្នុងកម្មវិធីអបអរសាទរ ទិវាសន្សំអាស៊ាន ក្រោមប្រធានបទ “សន្សំតិចប្រសើរជាងមិនបានសន្សំ”។ ក្រោមការរៀបចំឡើងដោយធនាគារជាតិនៃកម្ពុជា កម្មវិធីនេះមានគោលដៅផ្សព្វផ្សាយឲ្យកាន់តែទូលំទូលាយដល់សាធារណជន ដើម្បីបង្កើនការយល់ដឹងអំពីសារសំខាន់នៃការសន្សំ ក៏ដូចជាបរិយាបន្នហិរញ្ញវត្ថុនៅក្នុងតំបន់អាស៊ាន។

ទិវាសន្សំអាស៊ាន មានគោលបំណងលើកទឹកចិត្តប្រជាជនកម្ពុជាឲ្យមានទម្លាប់ល្អក្នុងការចាត់ចែងលុយកាក់ និងយល់ដឹងអំពីសារៈសំខាន់នៃការសន្សំសម្រាប់អនាគត។




## កិច្ចប្រជុំកំពូលអាស៊ាន - វេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុ

ធនាគារ ABA បានឧបត្ថម្ភថវិកាចំនួន **ពីរសែនដុល្លារអាមេរិក ($20,000)** ក្នុងវេទិកាបច្ចេកវិទ្យាហិរញ្ញវត្ថុនៃព្រឹត្តិការណ៍បច្ចេកវិទ្យាកម្ពុជា (CTX) 2022 ដែលធ្វើឡើងក្នុងផ្នែកមួយនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី 40 និង 41 ក្នុងរាជធានីភ្នំពេញ។

វេទិកានេះរៀបចំឡើងក្នុងគោលបំណងគាំទ្រ និងជំរុញសេដ្ឋកិច្ចឌីជីថល និងអភិវឌ្ឍបច្ចេកវិទ្យាហិរញ្ញវត្ថុនៅកម្ពុជា ដែលអនុញ្ញាតឲ្យធុរកិច្ចថ្មី (startups) និងបណ្តាក្រុមហ៊ុនក្នុងវិស័យបច្ចេកវិទ្យាហិរញ្ញវត្ថុ ចែករំលែកចំណេះដឹង បទពិសោធ និងឧត្តមានុវត្តន៍របស់ខ្លួន ជូនដល់សាធារណជន និយ័តករ និងអ្នកជំនាញបច្ចេកវិទ្យាហិរញ្ញវត្ថុ។

# ការគាំទ្រដល់វិស័យអប់រំ




## ពិព័រណ៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ កម្ពុជា-អន្តរជាតិ (CI-STI)

ធនាគារ ABA បានឧបត្ថម្ភក្នុងពិព័រណ៍វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ ដំបូងបង្អស់នៅកម្ពុជា កាលពីខែមីនា ឆ្នាំ 2023 ជាមួយកញ្ចប់ទឹកប្រាក់ **មួយម៉ឺនដុល្លារអាមេរិក ($10,000)**។ ពិព័រណ៍នេះ ត្រូវបានកំណត់យកជា ទិវាជាតិវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។

ពិព័រណ៍នេះត្រូវបានរៀបចំឡើងដោយ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងមានគោលបំណងបង្ហាញពីវឌ្ឍនភាពបច្ចេកវិទ្យាចុងក្រោយបង្អស់ ក្នុងវិស័យវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ ឆ្លៀតក្នុងឱកាសនេះដែរ ABA បានដាក់បង្ហាញនូវសេវាធនាគារឌីជីថលរបស់ខ្លួន ដែលគាំទ្រដល់បរិយាបន្នហិរញ្ញវត្ថុ នៅក្នុងប្រទេសផងដែរ។




## សមាគមសិស្ស-និស្សិតអាហារូបករណ៍
## សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត

ធនាគារ ABA បានចុះកិច្ចព្រមព្រៀង ជាមួយ សមាគមសិស្ស-និស្សិតអាហារូបករណ៍ សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត (AMT) ដើម្បីផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុដល់សមាគម។ ធនាគារ បានផ្តល់ថវិកាសប្បុរសធម៌ចំនួន **មួយសែនដុល្លារអាមេរិក ($100,000)** ដល់ AMT សម្រាប់គាំទ្រដល់ប្រជាជនកម្ពុជាតាមរយៈអាហារូបករណ៍ កម្មវិធីអប់រំដែលមាន និងគម្រោងជំនួយហិរញ្ញវត្ថុ។

AMT ជាអង្គការសប្បុរសធម៌មិនរកប្រាក់កម្រៃត្រូវបានបង្កើតឡើង ដើម្បីផ្តល់អាហារូបករណ៍ដល់គ្រួសារក្រីក្រ និងអភិវឌ្ឍធនធានមនុស្ស។

# គំនិតផ្តួចផ្តើម និងការគាំទ្រផ្សេងទៀត



ការគាំទ្រផ្នែកថវិកា សម្រាប់យុទ្ធនាការកីឡាវាយកូនបាល់កម្ពុជាដល់ Davis Cup ឆ្នាំ2021 និង 2022។



ការគាំទ្រផ្នែកថវិកា និងផ្តល់ការគាំទ្រផ្នែកសម្ភារជូនអង្គការ EmbraceAbility NPO ដើម្បីជួយសហគមន៍ក្រីក្រ។



ការគាំទ្រផ្នែកថវិកា និងផ្តល់ការគាំទ្រផ្នែកសម្ភារជូនអង្គការ Little Hearts NPO ដើម្បីជួយកុមារក្រីក្រ។



ការចូលរួមរបស់បុគ្គលិកក្នុងបេសកកម្មរបស់ TYDA នៅខេត្តកណ្តាល និងខណ្ឌដង្កោ រាជធានីភ្នំពេញ។



ការគាំទ្រផ្នែកថវិកាដល់ សហគមន៍រងគ្រោះដោយទឹកជំនន់ក្នុងខេត្តកំពង់ធំ និងសៀមរាបតាមរយៈសមាគមធនាគារនៅកម្ពុជា ក្រោមគំនិតផ្តួចផ្តើមរបស់ធនាគារជាតិនៃកម្ពុជា។




បរិច្ចាគសម្ភារសិក្សាសម្រាប់គាំទ្រគម្រោង Sipar’s Youth Employability ដែលបានចាប់ផ្តើមឡើងដើម្បីលើកកម្ពស់លទ្ធភាពការងារ និងការចូលរួមក្នុងវិស័យសង្គមស៊ីវិលរបស់យុវជននៅតំបន់ជនបទ។



ការគាំទ្រផ្នែកថវិកាដល់ សហគ្រិនខ្មែរ ក្នុងកម្មវិធីត្រៀមខ្លួនដើម្បីទទួលបានការវិនិយោគ ដែលជាអង្គភាពមួយស្ថិតក្រោមក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ទទួលបន្ទុកក្នុងការអនុវត្តកម្មវិធីគាំទ្រធុរកិច្ចថ្មី និងសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា។




ការឧបត្ថម្ភកម្មវិធី "ការប្រកួតប្រជែងសហគ្រិនស្ត្រី" ដែលជាគំនិតផ្តួចផ្តើមរបស់ WE Act Cambodia ក្នុងគោលបំណងចូលរួមជាមួយសហគ្រិនស្ត្រីវ័យក្មេង និងនិស្សិតសាកលវិទ្យាល័យដែលជាស្ត្រី ក្នុងការអភិវឌ្ឍន៍គំនិតអាជីវកម្មរបស់ពួកគេ។

www.ababank.com